ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំប្រទេសបារាំង

# សេចក្តីជូនដំណឹង

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំទីក្រុងប៉ារីស សូមជម្រាបជូនបងប្អូនប្រជាពលរដ្ឋខ្មែរ សិស្សនិងនិស្សិត ដែលកំពុងរស់នៅក្នុងប្រទេសបារាំង អេស្ប៉ាញ អ៊ីតាលី ព័រទុយហ្កាល់ ក្រិក ម៉ាល់តា ស៊ីប អង់ដូរ៉ា និងម៉ូណាកូ ឲ្យបានជ្រាបថា យោងស្ថានការថ្មីៗនេះដើម្បីទប់ស្កាត់ការរីករាលដាលនៃជំងឺកូវីដ១៩ រដ្ឋាភិបាលនៃប្រទេសជាច្រើន បានប្រកាសឲ្យ ប្រជាជនខ្លួនទាំងអស់ ស្ថិតនៅតែក្នុងផ្ទះ ដោយហាមមិនឲ្យធ្វើដំណើរចេញក្រៅផ្ទះ លើកលែងតែក្នុងករណីចាំបាច់បំផុត។ ទន្ទឹមនឹងនេះព្រំដែនក្រៅអឺរ៉ុប(ក្រៅលំហរ Schengen) ត្រូវបានបិទហាមមិនឲ្យជនបរទេសធ្វើដំណើរចេញចូលលើកលែងតែជនបរទេសណាដែលមានបំណងចាកចេញត្រឡប់ទៅប្រទេសខ្លួនវិញប៉ុណ្ណោះ។

សម្រាប់ប្រទេសបារាំង ចាប់តាំងពីថ្ងៃទី ១៧ ខែមីនា ឆ្នាំ២០២០ មក ហើយក្នុងរយៈពេលយ៉ាងតិច ១៥ ថ្ងៃ ការចេញពីផ្ទះអាចអនុញ្ញាតបានតាមលក្ខខណ្ឌខាងក្រោម៖

**ទី១** ការចេញពីផ្ទះទៅកន្លែងធ្វើការប្រសិនបើការងារនោះជាការងារចាំបាច់ហើយមិនអាចធ្វើពីផ្ទះបាន។
**ទី២** ការចេញពីផ្ទះទៅទិញម្ហូបអាហារចាំបាច់នៅក្នុងហាងទំនិញដែលអនុញ្ញាតឲ្យបើកទ្វារ។
**ទី៣** ការចេញពីផ្ទះក្រោមហេតុផលសុខភាពដើម្បីទៅជួបពេទ្យ។
**ទី៤** ការចេញពីផ្ទះក្រោមហេតុផលគ្រួសារមានបញ្ហាដែលត្រូវជួយបន្ទាន់ ពិសេសមនុស្សងាយរងគ្រោះ ឬការមើលកូនក្មេង។ ក្នុងករណីដែលប្តី ប្រពន្ធលែងលះគ្នាដែលមានកូន និងត្រូវមើលកូនម្តងម្នាក់ គេអាចចេញពីផ្ទះយកកូនទៅឲ្យគ្នាម្តងម្នាក់។
**ទី៥** ការចេញពីផ្ទះដោយស្ថិតក្បែរផ្ទះ ដូចយ៉ាងដើរហាត់ប្រាណបន្តិចបន្តួច ឬមួយនាំឆ្កែ ឬឆ្មាចេញក្រៅក្នុងរយៈពេលខ្លី។ តែហាមមិនឲ្យមានការហាត់ប្រាណជាក្រុម ជួបជុំជជែកជាមួយអ្នកជិតខាង ឬមួយជាមួយមិត្តភក្តិ។

4, rue Adolphe Yvon
75116 – PARIS (France)
Tél. : (33) 01 45 03 47 20
Fax : (33) 01 45 03 47 40

រដ្ឋាភិបាលបារាំងក៏បានសម្រេច ពន្យារសុពលភាពពិសេសរយៈពេល ៣ ខែ នៃការអនុញ្ញាតឱ្យស្នាក់នៅ ដែលបានចេញរួចហើយសម្រាប់ជនបរទេសនៅក្នុងប្រទេសបារាំងដូចជា៖

១-ទិដ្ឋាការស្នាក់នៅរយៈពេលវែង ( visa long séjour )
២-វិញ្ញាបនប័ត្រនៃការស្នើសុំសិទ្ធិជ្រកកោន
៣-ការអនុញ្ញាតឱ្យស្នាក់នៅបណ្តោះអាសន្ន ( carte de séjour )

ដូចច្នេះតាំងពី ថ្ងៃទី ១៧ ខែមីនា ឆ្នាំ ២០២០ មក ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសបារាំងបាន ធ្វើដំណើរការពីគេហដ្ឋាន ( télétravail ) ។ ក្នុងករណីបន្ទាន់និងចាំបាច់បំផុត បងប្អូនប្រជាពលរដ្ឋខ្មែរ សិស្ស និងនិស្សិត អាចទំនាក់ទំនងមកស្ថានទូតតាមរយៈ អ៊ីមែល arc@ambcambodgeparis.info គេហទំព័រ facebook និងទូរសព្ទ +33 7 53 39 34 89
និង +33 6 66 09 45 27 ។

សូមបងប្អូនប្រជាពលរដ្ឋទាំងអស់មេត្តាយកចិត្តទុកដាក់ខ្ពស់និងប្រុងប្រយ័ត្នបំផុតក្នុងការការពារសុខភាពរបស់ខ្លួន តាមរយៈការណែនាំរបស់អង្គការសុខភាពពិភពលោក និងគោរពតាមអនុសាសន៍និងសេចក្តីប្រកាសរបស់រដ្ឋាភិបាល នៃប្រទេសនីមួយៗ

ថ្ងៃសុក្រ ១២ រោច ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣
ប៉ារីស ថ្ងៃទី ២០ ខែមីនា ឆ្នាំ២០២០

AMBASSADE ROYALE DU CAMBODGE EN FRANCE

4, rue Adolphe Yvon
75116 – PARIS (France)
Tél. : (33) 01 45 03 47 20
Fax : (33) 01 45 03 47 40